ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៦៩...សសរ

# សេចក្ដីសម្រេច
## ស្ដីពីការបង្កើតក្រុមការងារចម្រុះ ទទួល និងដោះស្រាយបណ្ដឹងតវ៉ាផ្សេងៗ នៅមុខភូមិគ្រឹះសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់ ។

## ស ម្រេ ច

**ប្រការ ១ :** បង្កើតក្រុមការងារចម្រុះទទួល និងដោះស្រាយបណ្ដឹងតវ៉ាផ្សេងៗ នៅមុខភូមិគ្រឹះសម្ដេចអគ្គមហាសេនាបតីតេជោ និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម នាយឧត្តមសេនីយ៍ | **ហ៊ីង ប៊ុនហៀង** | អគ្គមេបញ្ជាការរង កងយោធពលខេមរភូមិន្ទ<br>នាយករងឧទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **ឃួង ស្រេង** | អភិបាលនៃគណៈអភិបាល រាជធានីភ្នំពេញ | អនុប្រធាន |
| ៣- ឯកឧត្តម | **ម៉ៅ ធិរុណ** | អភិបាលនៃគណៈអភិបាល ខេត្តកណ្ដាល | អនុប្រធាន |
| ៤- ឧត្តមសេនីយ៍ឯក | **ចៅ តុល** | នាយករងឧទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី<br>មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | អនុប្រធាន |
| ៥- ឧត្តមសេនីយ៍ឯក | **ស ថេត** | អគ្គស្នងការរង នគរបាលជាតិ<br>ស្នងការ ស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ | សមាជិក |
| ៦- ឧត្តមសេនីយ៍ឯក | **រ័ត្ន ស្រ៊ាង** | មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស<br>មេបញ្ជាការ កងរាជអាវុធហត្ថរាជធានីភ្នំពេញ | សមាជិក |
| ៧- ឧត្តមសេនីយ៍ឯក | **អ៊ុង សារិទ្ធ** | មេបញ្ជាការរង នាយសេនាធិការ<br>បញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ៨- ឧត្តមសេនីយ៍ឯក | **ខៀង សារុន** | មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ៩- ឧត្តមសេនីយ៍ឯក | **យ៉ាត ឆូច** | ក្រុមលេខាសម្ដេចតេជោ នាយករដ្ឋមន្ត្រី<br>មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | សមាជិកអចិន្ត្រៃយ៍ |
| ១០- ឧត្តមសេនីយ៍ឯក | **ណុប រ័ត្ននិមល** | ក្រុមលេខាសម្ដេចតេជោ នាយករដ្ឋមន្ត្រី<br>មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ១១- ឧត្តមសេនីយ៍ទោ | **អ៊ាង ចំរើន** | ស្នងការ ស្នងការដ្ឋាននគរបាល ខេត្តកណ្ដាល | សមាជិក |

| | | | |
|---|---|---|---|
| ១២- ឯកឧត្តម | **គង់ ចំរើន** | ក្រុមលេខាសម្ដេចតេជោ នាយករដ្ឋមន្ត្រី | សមាជិក |
| ១៣- ឯកឧត្តម | **នៅ រ៉ា** | ក្រុមលេខាសម្ដេចតេជោ នាយករដ្ឋមន្ត្រី | សមាជិក |
| ១៤- ឧត្តមសេនីយ៍ឯក | **ឃិន ចាន់ធួន** | មេបញ្ជាការ កងអនុភាគមន៍៥៩៤ (ប្រចាំការភ្នំពេញ) | សមាជិក |
| ១៥- ឧត្តមសេនីយ៍ឯក | **អ៊ិន សារិន** | មេបញ្ជាការរង កងអនុភាគមន៍ទី៨ (ប្រចាំការតាខ្មៅ) | សមាជិក |
| ១៦- លោក | **ស៊ុយ ឈុនហាក់** | មេធាវីប្រចាំបញ្ជាការដ្ឋានអង្គរក្ស | សមាជិក |
| ១៧- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | ០១ រូប | សមាជិក |
| ១៨- តំណាងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | | ០១ រូប | សមាជិក |
| ១៩- តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | | ០១ រូប | សមាជិក |
| ២០- តំណាងក្រសួងយុត្តិធម៌ | | ០១ រូប | សមាជិក |
| ២១- តំណាងក្រសួងព័ត៌មាន | | ០១ រូប | សមាជិក |
| ២២- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | ០១ រូប | សមាជិក។ |

**ប្រការ ២** : ក្រុមការងារចម្រុះ មានភារកិច្ច ៖

- ទទួលពាក្យបណ្ដឹងតវ៉ាផ្សេងៗ នៅមុខភូមិគ្រឹះសម្ដេចតេជោ និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិមានឯករាជ្យ រាជធានីភ្នំពេញ និង តាខ្មៅ ខេត្តកណ្ដាល រួចបញ្ជូនទៅជំនាញពាក់ព័ន្ធ ដើម្បីពិនិត្យសម្រេច រឺ ធ្វើរបាយការណ៍ជូនសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ទប់ស្កាត់ក្រុមអ្នកតវ៉ាមានបាតុករច្រើននាក់ដែលមានបំណងមកដាក់ពាក្យបណ្ដឹងតវ៉ាផ្សេងៗ ជូនសម្ដេចតេជោ និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ។
- ព្យាយាមពន្យល់អំពីនីតិវិធីជូនក្រុមអ្នកតវ៉ា ឱ្យយល់អំពីភារកិច្ចរបស់ក្រុមការងារចម្រុះ និងច្បាប់ជាធរមានផ្សេងៗ
- ទប់ស្កាត់រាល់ការញុះញង់ពីក្រុមឆ្លៀតឱកាសដែលកេងចំណេញមកលើក្រុមអ្នកតវ៉ា
- អនុប្រធាន និងសមាជិក ក្រុមការងារចម្រុះត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕ ✓

ថ្ងៃ សន្ទា ៧ កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាន នគរបាលជាតិ
- កងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ